# ៦. រឿង ទេវតាសេកសោយ

កាលពីព្រេងនាយ មានមនុស្សកម្សត់ពីរនាក់ប្ដីប្រពន្ធ មានកូនប្រុសមួយ ។ កូននោះកើតឡើងវេលាណា មានទេវតាអាក្រក់មកថែរក្សាសែកសោយ ។ តាំងពីទេវតាអាក្រក់មកសែកសោយក្មេងនោះ ឪពុកម្ដាយក៏ស្លាប់ចោលអស់ទៅ ។ ក្មេងនោះនៅជាមួយនឹងជីដូន ៗ ក៏ថែរក្សាដរាបដល់អាយុ ២០ ឆ្នាំ ។ ថ្ងៃមួយ ក្មេងនោះចូលទៅក្នុងព្រៃ ដើម្បីរកឧស កំពុងតែកាប់ឧស មានទេវតាមួយអង្គទៀត ជាទេវតាល្អ ជួយឲ្យចម្រុងចម្រើនយសស័ក្តិភោគសម្បត្តិ ។ ទេវានោះនិយាយនឹងទេវតាអាក្រក់ថា «តាំងពីអ្នកឯងចូលមករក្សាមនុស្សនោះកាលណា ម្ដាយអាពុកគ្នាស្លាប់ចោលអស់ហើយ គ្នាក្រលំបាកពន់ពេក ហើយថាឫទ្ធិអ្នកឯងពូកែមែន » ។ ទេវតាអាក្រក់និយាយតបទៅវិញថា « អ្នកជឿថាអំណាចខ្ញុំពូកែទេ? » ។ ទេវតាល្អឆ្លើយថា « ខ្ញុំជឿហើយ ប៉ុន្តែខ្ញុំសូមរក្សាមនុស្សនេះម្ដង» ។ ទេវតាអាក្រក់ ព្រមបើកអំណាចឲ្យទេវតាល្អថែរក្សាហើយហោះទៅ ។ ទេវតាបណ្ដាលឲ្យមនុស្សនោះកំពុងតែកាប់ឧស ក៏ដាក់ដឹងចុះហើយភ្ញាក់ខ្លួនព្រើតលោគិតថា «ឱ អញ បើអញរស់នៅ គ្រាន់អញនឹងរកស៊ីចិញ្ចឹមជីវិតជីដូនអញ បើប្រសិនជាអញស្លាប់ទៅ តើបានអ្នកណានឹងរកស៊ីចិញ្ចឹមជីដូនអញទៀត បើដូច្នេះ អញគិតទៅនិយាយបបួលយាយអញទៅនៅធ្វើខ្ញុំសេដ្ឋី គ្រាន់តែសុំបាយគេស៊ី ប្រហែលជាគេព្រមហើយ» គិតតែប៉ុណ្ណេះក៏លែងកាប់ឧស ត្រឡប់ទៅវិញ ទៅដល់និយាយប្រាប់ជីដូនតាមដំណើរសព្វគ្រប់ ដែលខ្លួនគិតកាលទៅកាប់ឧស ។ ជីដូនបានស្ដាប់ហើយក៏ចូលចិត្តព្រមតាមចៅ បុរសកម្សត់ទាំងពីរនាក់ គឺជីដូននិងចៅ ក៏នាំគ្នាដើរទៅផ្ទះមហាសេដ្ឋី ដល់ចូលទៅក្នុងកំពែងរបងហើយ ទៅអង្គុយបត់ជើងនៅមាត់ជណ្ដើរមហាសេដ្ឋី ។ លុះបន្តិចទៅ មហាសេដ្ឋីប្ដីប្រពន្ធនាំគ្នា ចេញមកក្រៅក្រឡេកទៅឃើញអ្នកទាំងពីរនាក់អង្គុយក៏សួរថា «ឯងមកនេះមានប្រាថ្នាអ្វី?» ។ បុរសកម្សត់នោះឆ្លើយជម្រាបទៅសេដ្ឋីថា «ខ្ញុំពីរនាក់ជីដូននិងចៅនេះ មកសុំនៅធ្វើជាខ្ញុំបម្រើលោក គ្រាន់តែយកបាយចិញ្ចឹមជីវិត» ។ មហាសេដ្ឋីស្ដាប់ហើយឆ្លើយថា « អើឯងនៅចុះ » ។ បុរសនោះជម្រាបទៅមហាសេដ្ឋីថា «សូមលោកមេត្តាឲ្យខ្ញុំនៅបម្រើខាងលើផ្ទះបាយហើយនិងផ្ទះធំ» ។ មហាសេដ្ឋីព្រម ទើបយាយចាស់នោះ សុំគ្រាន់តែដេញមាន់ទា កុំឲ្យស៊ីស្រូវ កាលណាគេយកស្រូវទៅហាល ។ បុរសនោះ ខំយកចិត្តទុកដាក់បម្រើសេដ្ឋីមិនឲ្យទាស់ចិត្តបន្តិចសោះ ។ មហាសេដ្ឋីមានចិត្តអាណិតស្រឡាញ់រាប់អាន ។ លុះយូរទៅប្រមាណជា ៣-៤ ឆ្នាំ បុរសនោះ សុំមហាសេដ្ឋីទៅនៅឃ្វាលក្របីវិញ ដល់នៅឃ្វាលក្របី ផ្លាស់អស់ខ្សែព្រួរចាស់ៗទាំងប៉ុន្មាន ជួសជុលក្រោលឲ្យស្អាតល្អឡើង ក្របីទាំងអស់ចំនួន ១០០ ក្បាល ។ ដល់យូរទៅមហាសេដ្ឋីប្ដីប្រពន្ធនិយាយគ្នាថា «តាំងពីអានេះទៅឃ្វាលក្របី យើងមិនដែលទៅមើលវាម្ដងសោះ ដូច្នេះត្រូវយើងនាំគ្នាទៅមើលវាម្ដង» ក៏នាំប្ដីប្រពន្ធទៅ លុះទៅដល់មើលទៅក្របី ខ្សែព្រួរ និងក្រោល ពេញចិត្តទាំងអស់ ក៏ត្រឡប់មកវិញនិយាយគ្នាថា «អានេះជាមនុស្សល្អ កាលដែលយើងឃើញមុន មិនដែលមានប្រដាប់សម្រាប់ក្របីថ្មី យ៉ាងនេះទេ ឥឡូវនេះមានព្រម អានេះជាមនុស្សចិត្តត្រង់នឹងចៅហ្វាយនាយ» ។ បុរសនោះទៅឃ្វាលក្របីរាល់ថ្ងៃ មានកាលថ្ងៃមួយនោះ ពេលល្ងាចដេញក្របីត្រឡប់មកក្រោលវិញ មកដល់ត្រពាំងមួយ ដេញក្របីចុះទៅត្រពាំងទឹក ទៅជាន់ដុំមាសនៅក្នុងត្រពាំងនោះ បែរទៅខាងណា ក៏សុទ្ធតែដុំមាស ពេញត្រពាំងទាំងអស់ ។ បុរសនោះថា «ដុំថ្មអ្វីក៏ច្រើនម្ល៉េះ ប៉ះជើងស្ទើរស្លាប់ហើយ » ថាហើយក៏យកដុំមាសមួយដុំមក គិតថា «អញយកដុំថ្មនេះទៅផ្ញើយាយអញ ព្រោះថ្មនេះល្អ» ។ បុរសនោះ ដេញក្របីមកចូលក្រោល រួចហើយក៏យកដុំមាសនោះទៅឲ្យជីដូនៗ បានឃើញដុំមាសហើយ

សួរថា «ចៅយកពីណាមក យកទៅវិញទៅយាយមិនហ៊ានយកទេ ដុំមាសធំម្ល៉េះ » ។ បុរសដឹងជាដុំមាសដូច្នោះហើយ ក៏យកទៅទុកក្នុងត្រពាំងវិញ ចំណាំកន្លែងទុក រួចត្រឡប់មកវិញ ។

ថ្ងៃក្រោយមក ព្រះមហាក្សត្រ ទ្រង់ល្បងចិត្តពួកសេនាបតី ទ្រង់មានព្រះបន្ទូលទៅនឹងអាមាត្យថា « អ្នកឯងទៅប្រាប់សេនាបតីទាំង៤ ថា « ល្ងាចនេះ ឲ្យដេកចាំព្រះបរមរាជវាំងនៅចុងព្រះរាជរោង» ។ អាមាត្យនាំយកព្រះបន្ទូលទៅជម្រាបសេនាបតីទាំង ៤ តាមដំណើរ ។ សេនាបតីទាំងនោះ ក៏រៀបខ្លួនមកដេកតាមព្រះរាជឱង្ការពេលមកដេកនោះ មិនគិតប្រុងប្រយ័ត្នសោះ គិតតែពីដេកទាល់ភ្លឺ ។ លុះយប់ជ្រៅស្ងាត់ ស្ដេចទ្រង់យាងមកទតសេនាបតីទាំង ៤ នោះ ឃើញដេកទាំងអស់គ្នា ក៏ទ្រង់យាងត្រឡប់ទៅក្រឡាព្រះបន្ទំវិញ ដល់ព្រឹកឡើង ទ្រង់មានព្រះបន្ទូលឲ្យចាប់សេនាបតីទាំងនោះ យកទៅកាប់ចោលទៅ ។ លុះល្ងាចក្រោយទៀត ទ្រង់មានព្រះបន្ទូលឲ្យហៅមហាសេដ្ឋីទាំង ៤ ឲ្យមកដេកដូចមុនទៀត ។ មហាសេដ្ឋីដែលជាចៅហ្វាយបុរសកម្សត់នោះ ភ័យណាស់ ព្រោះមិនដឹងជាមានរឿងអ្វីបានជាស្ដេចឲ្យសម្លាប់សេនាបតីទាំង ៤ មុននោះ ឥឡូវដល់មកខ្លួនទៀត គិតថាមុខជាស្លាប់ហើយ កូនប្រពន្ធទាំងប៉ុន្មានយំសោកទាំងអស់គ្នា ។ លុះបន្តិចទៅ ឮទៅដល់បុរសកម្សត់ៗ ក៏ឡើងមកសួរថា « ហេតុម្ដេច បានជាយំសោកយ៉ាងនេះ? » ។ មហាសេដ្ឋីប្រាប់ទៅតាមរឿង ។ បុរសថា « បើដូច្នេះ ខ្ញុំសូមទៅដេកជំនួស » ។ មហាសេដ្ឋីឮដូច្នោះហើយ ក៏អរណាស់ ឲ្យរកសំពត់អាវល្អៗ យកមកឲ្យបុរសកម្សត់នោះស្លៀកដោយគិតថា មុខជាស្លាប់ហើយ ។ លុះបុរសរៀបខ្លួនស្រេច នឹងទៅដេកចាំវាំង ជាមួយពួកមហាសេដ្ឋីឯទៀត តែពេលទៅ បុរសនោះយកទាំងដាវមួយទៅផង ទៅដល់ហើយក៏ដេក ។ ពួកមហាសេដ្ឋីឯទៀត គេអង្គុយនិយាយគ្នាលេង លុះដល់យប់ជ្រៅ ទើបនាំគ្នាដេកអស់ទៅ ។ បុរសនោះ ដឹងថាគេដេកស្ងាត់ ក៏ក្រោកឡើងអង្គុយម្នាក់ឯង ។ លុះយប់ជ្រៅស្ងាត់ ស្ដេចទ្រង់ចេញមកដូចមុនទៀត មកដល់ចុងព្រះរាជរោង បុរសនោះក្រឡេកឃើញទាញដាវបាន ដេញកាប់ធ្វើជាកាប់ផុតៗ ស្ដេចរត់រួចទៅ ។ ក្នុង ១ យប់នោះ ស្ដេចចេញមក ៣ ដង ។ បុរសដេញកាប់ទាំង ៣ ដងស្ដេចទ្រង់រត់ទៅវិញ ។ លុះព្រឹកឡើង ស្ដេចទ្រង់មានព្រះបន្ទូល ឲ្យចាប់សេដ្ឋីទាំង ៣ នាក់ ដែលដេកនោះ យកទៅកាប់ចោល ហើយទ្រង់មានព្រះបន្ទូលឲ្យហៅបុរសកម្សត់នោះទៅ ទ្រង់មានព្រះបន្ទូលសួរបុរសកម្សត់ថា «ឯងជាសេដ្ឋីឈ្មោះអ្វី?» ។ បុរសកម្សត់ក្រាបទូលថា « ទូលព្រះបង្គំជាខ្ញុំ ជាកូនមហាសេដ្ឋីឈ្មោះនោះ» ។ ស្ដេចមានព្រះបន្ទូលឲ្យទៅហៅមហាសេដ្ឋី ដែលជាចៅហ្វាយបុរសកម្សត់នោះមកទ្រង់មានព្រះបន្ទូលសួរថា «នេះជាកូនអ្នកមែនឬអ្វី? » ។

មហាសេដ្ឋីក្រាបទូលឆ្លើយទទួលថា «កូនមែន» ។ ស្ដេចមានព្រះបន្ទូលថា «បើកូនមហាសេដ្ឋីឯង អញសុំធ្វើជាកូនអញ» ។ មហាសេដ្ឋីក៏ថ្វាយបុរសនោះទៅស្ដេច ហើយក្រាបបង្គំលាទៅផ្ទះវិញ ។ ស្ដេចមានព្រះរាជបុត្រីមួយព្រះអង្គ ទ្រង់ក៏រៀបផ្សំផ្គុំនឹងបុរសកម្សត់នោះ ជាប្ដីប្រពន្ធទៅ ហើយអភិសេកឲ្យឡើងសោយរាជ្យយូរទៅ ស្ដេចបុរសនឹកឃើញទៅដល់មាស ដែលនៅក្នុងត្រពាំង ក៏ត្រាស់បង្គាប់ទៅមហាសេដ្ឋីឪពុក ឲ្យទៅដឹកមាសមកដាក់ឃ្លាំងទុក ។

មានមួយថ្ងៃ ស្ដេចបុរសនោះ ចង់ចេញទៅកាន់ចុងព្រះរាជរោង ឲ្យសេនាបតីគាល់ ក៏ទៅទូលស្ដេចឪពុកៗ ទ្រង់ហាមថា « ឯងជាតិជារាស្ត្រ បើចេញទៅត្រូវយកមហេសីទៅផង » ។ ស្ដេចបុរសទ្រង់យាងចេញទៅកាន់ចុងព្រះរាជរោង ជាមួយអគ្គមហេសី ពួកនាហ្មឺនទាំងពួងគាល់តៀបត្រា ។ វេលានោះ ទេវតាអាក្រក់ ដែលរក្សាបុរសនោះអំពី

ដើម ត្រឡប់មកវិញក៏ជួបទេវតាល្អ ហើយនិយាយថា «ឥឡូវនេះអ្នករក្សាមនុស្សនេះ តាំងពីនៅលំបាក ទាល់តែបានធ្វើជាស្តេចថែមទៀត នោះឃើញថាអំណាចអ្នកពូកែមែន បើបើដូច្នេះអ្នកចេញទៅ ឲ្យខ្ញុំរក្សាម្តង» ។ ទេវតាល្អ ប្រគល់ស្តេចកម្សត់ឲ្យទៅទេវតាអាក្រក់ហើយហោះ ទៅ ។ ពេលនោះ មានភ្លៀងផ្គរ ទេវតាអាក្រក់ក៏បណ្តាលចិត្តស្តេចបុរសនោះមួយរំពេច ស្តេចនោះមិនបានគិត លោមានព្រះបន្ទូលចំពោះពួកនាហ្មឺន ដែលគាល់ត្រៀបត្រាថា អញឮផ្គរលាន់ស្រណោះកាលនៅឃ្វាលក្របីពីដើមណាស់ » គ្រាន់តែប៉ុណ្ណោះ មហេសីឮក៏ស្ទុះទៅរកព្រះបិតាហើយក្រាបទូលថា « ព្រះវរបិតា មិនគួរឲ្យខ្ញុំម្ចាស់ទៅអាមនុស្សឃ្វាលក្របីនេះ សោះខ្ញុំម្ចាស់លែងយកហើយ ព្រោះវានិយាយចំមុខនាហ្មឺនដែលគាល់ត្រៀបត្រាថា « ឮផ្គរលាន់ ស្រណោះកាលនៅឃ្វាលក្របីពីដើម ខ្ញុំម្ចាស់ខ្មាសពួកនាហ្មឺនសព្វមុខមន្ត្រីណាស់ ខ្ញុំម្ចាស់មិនយកជាប្តីទេ» ។ ស្តេចបិតាឮដូច្នោះ ក៏ឲ្យចាប់ស្តេចនោះយកទៅដាក់គុកទៅ ។ ដាក់គុកបានពាក់កណ្តាលថ្ងៃ ទេវតាល្អដែលរក្សាមុននោះត្រឡប់មកវិញ ហើយនិយាយទៅនឹងទេវតាអាក្រក់ថា «អ្នកមានរឹទ្ធិណាស់ចូលមករក្សាភ្លាម ស្តេចបុរសបានជាប់គុកភ្លាម ដូច្នេះអ្នកអញ្ជើញទៅចុះ ទុកឲ្យខ្ញុំរក្សាវិញ» រួចហើយទេវតាល្អក៏បណ្តាលចិត្តស្តេចបុរសៗនឹកឃើញភ្លាមថា « អញមិនគួរភ្លាត់សំដីឲ្យទាល់តែជាប់គុកសោះ ប៉ុន្តែគ្មានអ្នកណាដឹងថាអញជាប់គុកនៅឡើយទេដូច្នេះអញបង្គាប់ទៅសេដ្ឋីឳពុកអញ ឲ្យយកមាសដែលមកពីក្នុងត្រពាំងនោះ ដំធ្វើជារូបក្របី ១០០ ដាក់ជើងពានមាស ១០០ យកមកឲ្យអញក្នុងថ្ងៃស្អែកនេះពីព្រឹក» គិតតែប៉ុណ្ណោះក៏ប្រើមេគុកឲ្យទៅប្រាប់សេដ្ឋីថា «ស្តេចមានព្រះបន្ទូលថា ឲ្យយកមាសដំធ្វើរូបក្របី ១០០ ដាក់លើជើងពានមាស ១០០ ហើយយកទៅថ្វាយស្តេចដល់កន្លែងទ្រង់» ។ សេដ្ឋីឮហើយ ក៏ហៅជាងទាំងពួង ឲ្យធ្វើក្នុងមួយយប់ឲ្យហើយលុះព្រឹកឡើង ឲ្យខ្ញុំស្រីសេដ្ឋី ១០០ នាក់ ទូលយកទៅថ្វាយស្តេចក្នុងព្រះរាជវាំង ។ ស្តេចបិតាក្មេកទតមកឃើញ ឲ្យអមាត្យរត់ទៅមើល ។ អាមាត្យមកក្រាបទូលវិញទ្រង់មានព្រះបន្ទូលឲ្យហៅអ្នកទូលក្របីនោះមក ហើយទ្រង់មានព្រះបន្ទូលថា «នាងឯងរាល់គ្នាយកក្របីមាសនេះទៅណា?» ។ ស្រីទាំងនោះថា « ខ្ញុំម្ចាស់យកមកថ្វាយព្រះអង្គ» ។ ស្តេចទ្រង់ជ្រាប ទ្រង់ឲ្យហៅព្រះរាជបុត្រីថាមហេសីស្តេចកម្សត់ ឲ្យចេញមកមើល ហើយមានព្រះបន្ទូលថា «កូនអើយ ! ដែលប្តីឯងវាថាស្រណោះកាលឃ្វាលក្របីនោះ មិនមែនក្របីសត្វទេ គឺរូបក្របីមាសនេះឯង កូនមើលក្របីនេះចុះ ល្មើយកូនកុំខឹងនឹងប្តី យកប្តីវិញទៅ » មានព្រះបន្ទូលតែប៉ុណ្ណោះក៏ទ្រង់ឲ្យទៅដោះស្តេចបុរសកម្សត់មក ហើយទ្រង់អភិសេកនឹងនាងជាព្រះរាជបុត្រីឲ្យឡើងសោយរាជសម្បត្តិ ជាសុខសប្បាយរៀងទៅ ព្រមទាំងយាយជីដូននៃបុរសនោះផង ។

**រិទ្ធិនៅទេវតា ប្រាជ្ញានៅមនុស្ស**